ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អគ្គិសនីកម្ពុជា

លេខ : ៧៧០៩/១៤ អសក.សកគ.ជប

# សេចក្តីជូនដំណឹង
## ស្តីពី ការជ្រើសរើសបុគ្គលិក

អគ្គិសនីកម្ពុជាសូមជម្រាបជូនដំណឹងដល់សាធារណៈជនថា អគ្គិសនីកម្ពុជា ត្រូវការជ្រើសរើសអ្នកបើកបររថយន្តស្ទូចចំនួន ០២ រូប ដើម្បីចូលបម្រើការងារ នៅអគ្គិសនីកំពង់ចាម នៃអគ្គិសនីកម្ពុជា ដូចខាងក្រោម:

*- **លក្ខណ:សម្បត្តិបេក្ខជន** :

- បេក្ខជនភេទប្រុស, មានអាយុចាប់ពី ១៨ ឆ្នាំ ដល់ ៣៥ ឆ្នាំ
- បៀវត្សរ៍ផ្តល់ជូន : បៀវត្សរ៍សុទ្ធ E.III.1 ក្នុងពេលសាកល្បងការងារ ០៣ ខែ ទទួលបាន 90%
- កម្រិតវប្បធម៌ : ចេះអាននិងសរសេរអក្សរខ្មែរបាន និងមានប័ណ្ណបើកបររថយន្តធុនធំ ។

*- **បញ្ជាក់** : បេក្ខជនគ្រប់ខេត្ត-ក្រុង ដែលមានអាសយដ្ឋានស្ថិតនៅខេត្តសាមី ប្រសិនបើលទ្ធផលពិន្ទុប្រហាក់ប្រហែលគ្នា គឺត្រូវផ្តល់អាទិភាព។

*- **បេក្ខជនត្រូវមកដាក់ពាក្យ និង ភ្ជាប់មកជាមួយនូវ** :

- ពាក្យសុំចូលបម្រើការងារ មានបិទតែមប្រើ(១.០០០ រៀល) ចំនួន ០១ ច្បាប់
- ប្រវត្តិរូបសង្ខេប មានបិទរូបថត ៤ x ៦ ចំនួន ០១ ច្បាប់
- សេចក្តីចម្លងសំបុត្របញ្ជាក់កំណើត ឬអាចយក សៀវភៅគ្រួសារឬអត្តសញ្ញាណប័ណ្ណ(ច្បាប់ចម្លងមានបញ្ជាក់ពី សាលារាជធានីភ្នំពេញ ឬសាលាខេត្ត)ឬលិខិតបញ្ជាក់ទីលំនៅ ចុះហត្ថលេខាពីខណ្ឌ-ស្រុក ចំនួន ០១ ច្បាប់
- លិខិតបញ្ជាក់កិរិយាមារយាទ ចំនួន ០១ ច្បាប់
- លិខិតបញ្ជាក់សុខភាព(ចេញដោយនាយកដ្ឋានពេទ្យការងារ នៃក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ)ចំនួន ០១ ច្បាប់
- ច្បាប់ចម្លងសញ្ញាប័ត្រចំណេះដឹងទូទៅមានបញ្ជាក់ពីសាលារាជធានីភ្នំពេញ ឬសាលាខេត្ត ចំនួន ០១ ច្បាប់
- ច្បាប់ចម្លងប័ណ្ណបើកបររថយន្តធុនធំ ចំនួន ០១ ច្បាប់
- លិខិតបញ្ជាក់ ឬ ច្បាប់ចម្លងសញ្ញាប័ត្រផ្សេងៗ (បើមាន) ចំនួន ០១ ច្បាប់
- លិខិតបញ្ជាក់ពីបទពិសោធន៍ការងារ (បើមាន) ចំនួន ០១ ច្បាប់

*- **ទីកន្លែងទទួលពាក្យ** :សាលប្រជុំអគារ C ជាន់ទី៣ នៃអគ្គិសនីកម្ពុជា

ចាប់ពីថ្ងៃផ្សាយដំណឹងនេះ រហូតដល់ថ្ងៃទី២២ ខែសីហា ឆ្នាំ២០១៤ រៀងរាល់ថ្ងៃធ្វើការ

- ពេលព្រឹក ចាប់ពីម៉ោង ០៨ : ០០ ដល់ម៉ោង ១១ : ៣០
- ពេលល្ងាច ចាប់ពីម៉ោង ១៤ : ០០ ដល់ម៉ោង ១៧ : ០០
- ពាក្យសុំចូលបម្រើការងារ ត្រូវប្រើប្រាស់គំរូ មានបោះត្រាសម្គាល់របស់អគ្គិសនីកម្ពុជា។

*- **ព័ត៌មានផ្សេងៗ** : សូមអញ្ជើញមកទាក់ទងការិយាល័យរដ្ឋបាល នៃទីស្នាក់ការកណ្តាល អគ្គិសនីកម្ពុជា ឬតាមរយៈលេខទូរស័ព្ទ ០២៣ ៧២៣ ៩៧១ និង ០២៣ ៧២៤ ៧៧១។

រាជធានីភ្នំពេញ,ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១៤

ជ. ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា

ទទួលបន្ទុកជា អគ្គនាយកអគ្គិសនីកម្ពុជា

អគ្គនាយករង

អេង_គន្ធា